ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ហលាដំបូងខេត្តកំពង់ចាម
សំណុំរឿងរដ្ឋប្បវេណី
លេខ១៦
ៈថ្ងៃទី១៦ ខែ០១ ឆ្នាំ២០២០
សាលក្រម
លេខ ៨៥ "គ"
ៈថ្ងៃទី២២ខែ០៤ឆ្នាំ២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពង់ចាម**

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី០៨ ខែ០៤ ឆ្នាំ២០២០
ប្រកាលសេចក្តីសម្រេចបញ្ចប់នៅថ្ងៃទី២២ ខែ០៤ ឆ្នាំ២០២០
សមាសភាពចូលរួមដូចតទៅៈ

**ចៅក្រម**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ចាម

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម

**គូភាគី**

១-ដើមចោទឈ្មោះ [redacted] **ច័ន** ភេទស្រី អាយុ៨៦ឆ្នាំ ជាតិខ្មែរ [redacted]។

អ្នកតំណាងដោយអាណត្តិ លោកស្រី មេធាវី [redacted]

២-ចុងចំលើយឈ្មោះ [redacted] **ស៊ាងហៃ** ភេទប្រុស អាយុ៦៧ឆ្នាំជាតិខ្មែរ [redacted]

អ្នកតំណាងដោយអាណត្តិ លោក មេធាវី [redacted]

**I-អង្គហេតុ និង ចំណុចវិវាទ**

**១-សញ្ញាណរឿងក្តីៈប្តឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចតទៅៈ**

១-១-សុំមោឃភាពលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី០៩ ខែ០១ឆ្នាំ២០១៥។

១-២-ប្តឹងទាមសិទ្ធិលើកម្មសិទ្ធិដីស្រែ ដែលមានវិញ្ញាបនបត្រសំគាល់អចលនវត្ថុលេខ ០៣០៦០៩១៣-០៤១៥ ។

១-៣-សុំអោយចុងចំលើយបញ្ឈប់ការបង្កបង្កើតផលលើដីស្រែនេះ។

១-៤-សុំសោហ៊ុយចំនួន១០លានរៀល។

១-៥-សុំឲ្យចុងចំលើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី។

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី**

-ដើមចោទឈ្មោះ [redacted] **ច័ន** (អវត្តមាន)

-លោក មេធាវី [redacted] ថ្លែងការណ៍ថា នៅក្នុងរឿងនេះខ្ញុំរក្សាតាម

Scanned with CamScanner

បណ្តឹងដែលបានដាក់ជូនតុលាការ ហើយរក្សាការទាមទារដដែល ។

ចំណុចនេះមាន០៦ចំណុចដែលមានលំអិតអស់ហើយ កន្លងមកដើមចោទបានថ្លែងការណ៍នូវរឿងនេះអស់ហើយដែរ។

តាមកូនក្តីខ្ញុំថា កូនរបស់ខ្លួនឈ្មោះ [redacted] ស៊ាងហៃ បានខ្ចីដីគាត់យកមកដាក់បញ្ចាំធនាគារ ដើម្បីយកលុយរកស៊ី ខ្លួនពិតជាមិនបានអោយទៅ [redacted] ស៊ាងហៃ ជាកម្មសិទ្ធិទេ ដោយខ្លួនមានតែដីនេះទុកសំរាប់ខ្លួន កូនៗបានទទួលចំណែកអស់ហើយ។

-ចុងចំលើយឈ្មោះ [redacted] **ស៊ាង ហៃ** ថ្លែងការណ៍តបថា ខ្ញុំទុកអោយមេធាវីខ្ញុំជាអ្នកថ្លែងការណ៍ជំនួសរូបខ្ញុំទៅចុះ។

-លោក មេធាវី [redacted] ថ្លែងការណ៍ថា នៅក្នុងរឿងនេះខ្ញុំរក្សានូវសេចក្តីថ្លែងការណ៍របស់កូនក្តីទុកនៅដដែល។

ខ្ញុំជាតំណាងដោយអាត្តិអោយចុងចំលើយគឺសុំធ្វើសេចក្តីថ្លែងការណ៍បន្ថែមទៅលើសេចក្តីរបស់កូនក្តីដូចតទៅនេះ

ពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិកាន់កាប់រវាងកូនក្តីខ្ញុំ និង ដើមចោទឈ្មោះ [redacted] វ៉ន ចុះថ្ងៃទី០៩ ខែ០១ឆ្នាំ២០១៥គឺជាកិច្ចសន្យាដែលធ្វើឡើងដោយប្រទានកម្ម និងដោយមានការព្រមព្រៀងគ្នា មិនដូចដើមចោទអះអាងថាគ្រាន់តែជាការផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី បណ្តោះអាសន្ននោះទេ ម្យ៉ាងវិញទៀតលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី១៩ ខែ១០ឆ្នាំ២០១៥ គឺធ្វើឡើងក្រោយពីការផ្ទេរសិទ្ធិអោយកូនក្តីខ្លួន ដូច្នេះដីដែលមានវិញ្ញាបនបត្រសំគាល់អចលនវត្ថុលេខ០៣០៦០៩១៣-០៩១៥ ចុះថ្ងៃទី០៤ ខែ០៥ ឆ្នាំ២០១០ដែលចេញដោយមន្ទីរសុរិយោដីខេត្តកំពង់ចាម នោះ គឺដើមចោទមិនអាចធ្វើប្រទានកម្មមិនអាចធ្វើការផ្ទេរសិទ្ធិកាន់កាប់ចំនួន០២ដងបានទេ ចំណែកឯការផ្ទេរសិទ្ធិកាន់កាប់របស់ដើមចោទទៅអោយចៅឈ្មោះ [redacted] សុវណ្ណ ដែលឈ្មោះនេះមិនមែនជាសន្តតិជនក្នុងការទទួលមរតិកពីពុក និងម្តាយរបស់កូនក្តីខ្ញុំឡើយ ។កូនក្តីខ្ញុំបាទជាសន្តតិជនមានសិទ្ធិទទួលមរតក និង មានសិទ្ធិទទួលការផ្ទេរសិទ្ធិកាន់កាប់ដូចក្នុងលិខិតផ្ទេរនេះ ដែលបានព្រមព្រៀងគ្នាកន្លងមក ។

ការបង្ហាញឆន្ទៈមិនមានការបង្ខិតបង្ខំទេ គឺម្តាយបានអោយទៅកូនពិតប្រាកដ។

សំណូមពរ សុំអោយតុលាការច្រានចោលការទាមទាររបស់ដើមចោទ ចោលជាអាសារបង់និងស្នើសុំអោយចៅក្រមលើកបណ្តឹងចោល។

-លោក មេធាវី [redacted] ថ្លែងការណ៍តបថា ចំពោះលិខិតផ្ទេរសិទ្ធិអោយទៅឈ្មោះ [redacted] ស៊ាងហៃ ជាកូននិងកូនប្រសារ គឺជាការផ្ទេរអោយកូនដើម្បីធ្វើការខ្ចីប្រាក់ យកមកដោះស្រាយជីវភាពផ្ទាល់ខ្លួនដោយខ្ចីតែប្លង់ដែលមានឈ្មោះ [redacted] វ៉ន និង លោក ហង់ហាន(ឪពុក និងម្តាយ)ធនាគារគេពុំព្រមទទួលយក ដូច្នេះហើយគាត់សុំអង្វរសុំខ្ចីប្លង់ និង ផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីរយៈពេល១ឆ្នាំយកទៅ

Scanned with CamScanner

ដាក់បញ្ចាំ។កន្លងមកគាត់ទាមទារយកដីមកវិញ គាត់ពុំព្រមអោយ ដោយគាត់ថា នៅជំពាក់គេនៅឡើយ ចាំគាត់រកលុយបាន គាត់នឹងបង់ផ្តាច់ពីធនាគារអោយហើយសិន ។ ដោយភាពចាំបាច់ពីព្រោះតែខ្លួនគាត់ចាស់ ហើយគាត់ទៅរស់នៅជាមួយនឹង[redacted]នាង ហៅ [redacted] ណារី និង មានប្តីឈ្មោះថា[redacted]សុវណ្ណ ដែលនៅក្នុងសៀវភៅគ្រួសារ ដាក់ជាកូនរបស់គាត់ដែលពេលនោះឈ្មោះ[redacted] ស៊ាងហៃ បានធ្វើជាសាក្សីព្រមប្រគល់ដីនេះនៅថ្ងៃទី១៩ ខែ១០ ឆ្នាំ២០១៥ ដែលធ្វើក្រោយលិខិតផ្ទេរសិទ្ធិរវាងលោកស្រី [redacted] វន និង ប្តីឈ្មោះ[redacted]ហាន បានផ្ទេរអោយ[redacted] ស៊ាងហៃ ជាកូន ថ្ងៃទី០៩ខែ០១ ឆ្នាំ២០១៥ នេះសបញ្ជាក់អោយឃើញថា ការផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីរបស់លោកស្រី [redacted] វន ទៅអោយ[redacted] ស៊ាងហៃ ជាកូន គឺជាការផ្ទេរសិទ្ធិ ដើម្បីអោយកូនយកទៅខ្ចីប្រាក់តែប៉ុណ្ណោះ រីឯការផ្ទេរសិទ្ធិរបស់លោកស្រី [redacted]វន ទៅអោយឈ្មោះ[redacted]នាង ហៅ[redacted]ណារី និង ប្តីឈ្មោះ[redacted]សុវណ្ណ គឺជាការផ្ទេរដោយឆន្ទៈពិតប្រាកដ។បើពិនិត្យលើច្បាប់ មាត្រា៥៧១ និងមាត្រា៥៧២នៃក្រមរដ្ឋប្បវេណី គឺម្ចាស់ប្រទានកម្មបានសុំយកមកជាកម្មសិទ្ធិវិញ ដោយរឿងនេះមានមេភូមិត្រកូនឈ្មោះ[redacted]ហុក ជាសាក្សីដឹងលឺនៃការធ្វើកិច្ចសន្យា។

សំណូមពរ

១-សុំមោឃភាព លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ០១៥។

២-សុំគ្រប់គ្រងជាម្ចាស់កម្មសិទ្ធិលើដីដែលមានវិញ្ញាបនបត្រសំគាល់អចលនវត្ថុលេខ០៣០៦ ០៩១៣-០៩១៥ ចុះថ្ងៃទី០៤ ខែ០៥ ឆ្នាំ២០១០ដែលចេញដោយមន្ទីរសុរិយោដីខេត្តកំពង់ចាម។

៣-សុំអោយចុងចំលើយបញ្ឈប់បង្កបង្កើនផលលើដីស្រែរបស់កូនក្តីខ្ញុំបាទ។

-លោកមេធាវី [redacted] ថ្លែងការណ៍តបថា ខ្ញុំសុំបដិសេធសេចក្តីថ្លែងការណ៍របស់មេធាវីដើមចោទ ដោយសុំបញ្ជាក់ថា កិច្ចសន្យារវាងកូនក្តីខ្ញុំ និង ម្តាយខ្ញុំគឺត្រឹមត្រូវតាមច្បាប់ ដោយទៅតាមឆន្ទៈរបស់គាត់ ចំណុចមួយទៀតដែលថាខ្ញុំធ្វើខ្ចីយកដាក់ធនាគារគឺមិនពិតទេ ដោយការខ្ចីធនាគារធ្វើឡើងក្រោយខណៈគាត់ផ្ទេរអោយហើយ។លិខិតផ្ទេរទៅអោយចៅឈ្មោះ[redacted]សុវណ្ណ និង[redacted] ណារី គឺធ្វើឡើងដោយខ្លួនមិនដឹងទេ កាលនោះផ្តិតនៅលើឡានរបស់[redacted]សុវណ្ណ នៅឆ្នាំ២០១៨ មិនមែននៅឆ្នាំ២០១៥ទេ ទើតែដឹងនៅពេលទទួលពាក្យបណ្តឹងនេះ។ សុំអោយចៅក្រមពិចារណាថាការធ្វើផ្ទេរកូនក្តីខ្ញុំគឺធ្វើឡើងមុន ហើយមេភូមិបានធ្វើការផ្ទេរចំនួន២ដង។

-សាក្សីឈ្មោះ[redacted] **ហុក** ថ្លែងការណ៍ថា ខ្ញុំជាមេភូមិត្រកូន ។ចំពោះលិខិតផ្ទេរសិទ្ធិរវាងឈ្មោះ[redacted]ស៊ាងហៃ និង[redacted]វន គឺខ្ញុំបានចុះហត្ថលេខាពិតប្រាកដ កាលនោះខ្ញុំបានប្រកែកថា ដីមានប្លង់ហើយមិនបាច់មានការវាស់វែងទេ បន្ទាប់ហង់[redacted]ហៃ បានយកលិខិតនេះទៅផ្តិតមេដៃម្តាយខ្លួន និងអ្នកផ្សេងរួចយកមកអោយខ្ញុំចុះហត្ថលេខាលើកិច្ចសន្យា បានបន្តិចធនាគារមកយកកិច្ចសន្យានេះ ដោយសុំអោយខ្ញុំជាមេភូមិបានជួយធានាទៀតទើបគេព្រមអោយលុយនេះ។យកមកនេះគឺដំបូងឈ្មោះ[redacted]ហៃ ហៅមៅមកក្រដាសស បន្ទាប់ខ្ញុំអោយក្រដាសទៅរួចមកវិញគាត់បានកាន់ប្លង់មកអោយខ្ញុំជួយចុះហត្ថលេខា

Scanned with CamScanner

ដោយបានដឹងថាគាត់យកលុយធនាគារ។ ក្រោយមកមានលិខិតទី២គឺឈ្មោះហាប់សុវណ្ណ បានមកដល់ផ្ទះ រួចអោយធ្វើលិខិតផ្ទេរសិទ្ធិមកអោយខ្លួន ហើយខ្ញុំសួរនាំអំពីប្លង់ដី ថាប្លង់នៅ[redacted]ហៃ ហៅ អាម៉ៅ វាមិនទាន់អោយដោយថាបង់ធនាគារមិនទាន់រួច និយាយនោះមានតា[redacted]ហាននិង យាយ [redacted] វ៉ន មកផ្ទាល់ និងមានកូនៗអ្នកនៅជុំវិញ ដោយការអេះអាងច្បាស់ ទើបខ្ញុំបានសរសេរនៅជុំគ្នា មាន[redacted]ស៊ាងហៃហៅអាម៉ៅ នៅនឹងនេះ ហើយមានកូនមកមិនគ្រប់ គឺនៅកូននៅសៀមរាប អត់បានមកទេ ។នៅចំពោះនោះឈ្មោះ [redacted] ស៊ាងហៃ មកផ្តិតដែរ ។តា[redacted]ហាន និងយាយ វ៉ន ពួកគាត់មិនវង្វេងទេ ដឹងថា ប្លង់នៅនឹងកូនគាត់ ស៊ាងហៃហៅអាម៉ៅ ដឹងថាកូននេះនៅជំពាក់ធនាគារទៀត ហើយខ្ញុំបានណែនាំខ្លះដែរអំពីការផ្ទេរ។ ចំពោះលិខិតទី១គឺមានលេខមេឃុំចុះលេខ និងហត្ថលេខា ត្រឹមត្រូវ ហើយលិខិតទី២ ក៏ជាលេខមេឃុំចុះលេខ និងចុះហត្ថលេខាត្រឹមត្រូវដែរ តែលិខិតទាំងអស់ខ្ញុំមិនចាំលេខ និងថ្ងៃ ខែ ឆ្នាំទេពីព្រោះយូរឆ្នាំ ។ ចំពោះឯកសារទី២ មានកូនៗមកចំពោះមុខមានឈ្មោះ[redacted]ចន្ទី និង [redacted] ឈាង ផ្តិតរួច ទើប[redacted]ស៊ាងហៃ បានមកផ្តិតមេដៃក្រោយគេ។ដំបូងគឺស៊ាងហៃមិនមកទេ ដោយហេតុតែខ្ញុំបានហៅ[redacted]ស៊ាងហៃ មិនមក លុះខ្ញុំបានទៅជួប និយាយគ្នា ដោយ[redacted]ស៊ាងហៃ បានជជែកថានឹងអោយដីទៅអ្នកផ្សេង ហើយថាប្លង់នៅនឹងខ្លួន មិនទាន់ផុតលុយធនាគារនៅឡើយ។

លិខិតដែលធ្វើអោយ[redacted]ហៃ ហៅម៉ៅ ដំបូងខ្ញុំមិនព្រមទេ រហូតគាត់អង្វរពេក និងបានអោយលុយមកខ្ញុំ១០០ដុល្លារ ទើបខ្ញុំជួយស៊ីញ៉េទៅ។

-លោក[redacted] **ស៊ាងហៃ** ថ្លែងការណ៍តបថា កាលផ្តិតមេដៃនោះមិនបានដឹងថាប្លង់ដីនេះទេ ដោយមានដីផ្សេងទៀត ស្មានថា ផ្តិតអោយដីផ្សេង ដោយយប់ងងឹត មិនបានមើល ប្រញ៉ាប់ពេក។

ចំលើយមេភូមិគឺខុសទាំងស្រុងដោយលិខិតខ្ញុំគាត់សរសេរផ្ទាល់ ។ លិខិតផ្ទេរខ្ញុំគឺខ្ញុំអោយគាត់១០០ដុល្លារ។

**២-ការពិនិត្យភស្តុតាង**

២-១-ភស្តុតាងជាឯកសាររបស់ដើមចោទ

-វិញ្ញាបនបត្រសំគាល់អចលនវត្ថុលេខ០៣០៦០៩១៣-០៩១៥ ចុះថ្ងៃទី០៤ ខែ០៥ ឆ្នាំ២០១០ ដែលចេញដោយមន្ទីរសុរិយោដីខេត្តកំពង់ចាម។

២-២-ភស្តុតាងដែលផ្តល់ដោយចុងចំលើយ

លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ០១៥។

**៣-សេចក្តីសន្និដ្ឋានរបស់មេធាវី**

-លោកស្រី មេធាវី [redacted]សន្និដ្ឋានថា កូនក្តីខ្ញុំជាម្ចាស់កម្មសិទ្ធិនៃដីដែលមានប័ណ្ណសំគាល់កម្មសិទ្ធិលេខ០៣០៦០៩១៣-០៩១៥ ចុះថ្ងៃទី០៤ ខែ០៥ ឆ្នាំ២០១០ ដែលចេញដោយមន្ទីរសុរិយោដីខេត្តកំពង់ចាម ហើយក៏ត្រូវជាម្តាយរបស់ឈ្មោះ[redacted]ស៊ាងហៃ ។នៅពេលនេះកូនក្តីខ្ញុំបានសុំអោយកូនប្រគល់

Scanned with CamScanner

ដីនេះមកអោយខ្លួនវិញ និងសុំអោយប្រគល់ប្លង់មកអោយខ្លួនវិញ ខ្លួនមិនសុខចិត្តអោយទៅឈ្មោះហាង់ ស៊ាងហៃទេ ។ការធ្វើលិខិតផ្ទេរកន្លងមកគឺបំពេញបំណងអោយឈ្មោះ[redacted] ស៊ាងហៃ ជាកូនខ្លួនដើម្បីយកទៅខ្ចីលុយធនាគារ ។បើពិនិត្យលើច្បាប់ មាត្រា៥៧១ និងមាត្រា៥៧២នៃក្រមរដ្ឋប្បវេណី គឺម្ចាស់ប្រទានកម្មបានសុំយកមកជាកម្មសិទ្ធិវិញ ដោយរឿងនេះមានមេភូមិត្រកួនឈ្មោះ[redacted]ជាសាក្សីដឹងលឺនៃការធ្វើកិច្ចសន្យា។

-លោកមេធាវី [redacted] សន្និដ្ឋានថា រឿងនេះគឺលិខិតកូនក្តីខ្ញុំជាលិខិតមុន ហើយនៅឯកសារមានដល់២ ដែលលិខិតទី២ ជាលិខិតក្រោយ។ ខាងអាជ្ញាធរបានធ្វើលិខិត០២ ដែលលិខិតទី២ មិនមានស្នាមមេដៃហាង់ ឈាង នោះទេ។

## **សំអាងហេតុ**

-តាមលទ្ធផលនៃការសាកសួរភាគី និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ឃើញថា៖

១-ទទួលស្គាល់ពាក្យបណ្តឹងចុះថ្ងៃទី១២ខែ០២ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ[redacted]វ៉ន ទុកជាត្រឹមត្រូវតាមច្បាប់។

២-ដើមចោទនិងចុងចំលើយត្រូវជាកូន និង ម្តាយបង្កើត ហើយបានទំនាស់គ្នាលើដីដែលមានមានប័ណ្ណសំគាល់កម្មសិទ្ធិលេខ០៣០៦០៩១៣-០៤១៥ ចុះថ្ងៃទី០៤ ខែ០៥ ឆ្នាំ២០១០ ដែលចេញដោយមន្ទីរសុរិយោដីខេត្តកំពង់ចាម ។ឃើញថាដីនេះមិនទាន់ផ្ទេរកម្មសិទ្ធិនៅឡើយទេ តែចុងចំលើយជាកូនបានកំពុងគ្រប់គ្រង អាស្រ័យផលលើ តែបើតាមកម្មវត្ថុគឺម្តាយសុំទាមទារយកមកគ្រប់គ្រង និង អាស្រ័យផលដោយផ្អែកថាដីនេះជាកម្មសិទ្ធិរបស់ខ្លួន។

៣-ដើមចោទបានប្តឹងសុំលើចំណុចទី១ គឺ១ទាមទារដីជាកម្មសិទ្ធិលើដីដែលមានវិញ្ញាបនបត្រសំគាល់អចលនវត្ថុលេខ០៣០៦០៩១៣-០៤១៥ មានលក្ខណៈត្រឹមត្រូវដោយឈ្មោះនៅក្នុងប័ណ្ណសំគាល់អចលនវត្ថុមានឈ្មោះស៊ឹម វ៉ន ជាម្ចាស់កម្មសិទ្ធិ ។ចំណែកលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ០១៥ គឺធ្វើឡើងមិនត្រឹមត្រូវតាមច្បាប់ទេ ដែលមានការអះអាងពីលោកប្រធានភូមិត្រកួនបញ្ជាក់ថា ជាការធ្វើឡើងដើម្បីតម្រូវការរបស់ឈ្មោះ[redacted]ហៃហៅម៉ៅ ដើម្បីយកលុយធនាគារដោះស្រាយជីវភាពខ្លួន ។

៤-ផ្អែកលើចំណុចការប្តឹងសុំនៅចំណុចទី១ គឺដោយដើមចោទជាម្ចាស់កម្មសិទ្ធិ និងត្រូវជាម្តាយរបស់ចុងចំលើយផងនោះ ដែលបានប្តឹងសុំយកដីខ្លួនមកវិញ គឺត្រឹមត្រូវតាមច្បាប់ ដោយដីនេះមិនទាន់បានផ្ទេរកម្មសិទ្ធិនៅសុរិយោដីនៅឡើយទេ ហើយបើពិនិត្យលើចំណុចនៃក្រមរដ្ឋប្បវេណីនៃមាត្រា៥៧១ និងមាត្រា ៥៧២ គឺម្ចាស់អាចលុបចោលនូវប្រទានកម្មវិញបាន ម្យ៉ាងមួយវិញដើមចោទ និង ចុង

Scanned with CamScanner

ចំលើយកន្លងមកបានទៅធ្វើការផ្ទេរលើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ០១៥ គឺធ្វើឡើងមិនត្រឹមត្រូវតាមច្បាប់ទេ ដោយមិនបានទៅចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃច្បាប់ស្តីពីការចុះបញ្ជី តាមត្រា១៣៣ មាត្រា១៣៤ និងមាត្រា១៣៥នៃក្រមរដ្ឋប្បវេណី គប្បីលុបចោល។

៥-សុំអោយចុងចំលើយបញ្ឈប់ការបង្កបង្កើតផលលើដីស្រែនេះ ចំណុចនេះតុលាការច្រានចោលការទាមទារ ។

៦-សុំសោហ៊ុយចំនួន១០លានរៀល តុលាការគប្បីច្រានចោល។

៧-សុំឲ្យចុងចំលើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីទាំងអស់ គប្បីអនុវត្តតាមមាត្រា៦៤កថាខ័ណ្ឌទី១នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>សេចក្តីសំរេចបញ្ចប់</u>

១-មោឃៈភាពលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ០១៥ រវាងដើមចោទឈ្មោះ [redacted] និងឈ្មោះ [redacted] **ស៊ាងហៃ** ចោល។

២-ប្រគល់សិទ្ធិជាកម្មសិទ្ធិលើដីដែលមានប័ណ្ណសំគាល់កម្មសិទ្ធិលេខ០៣០៦០៩១៣-០៩១៥ ចុះថ្ងៃទី០៤ ខែ០៥ ឆ្នាំ២០១០ ដែលចេញដោយមន្ទីរសុរិយោដីខេត្តកំពង់ចាម អោយទៅដើមចោទឈ្មោះ [redacted] ជាអ្នកគ្រប់គ្រង។

៣-ចុងចំលើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីទាំងអស់ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ដែលដើមចោទបានបង់រួចហើយ តែចុងចំលើយត្រូវបង់ប្រាក់ប្រដាប់ក្តីនេះឲ្យទៅដើមចោទវិញនៅពេលសាលក្រមចូលស្ថាពរ។

៥-សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ចំពោះមុខគូភាគី និង ប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែ០៤ ឆ្នាំ២០២០ ចំពោះមុខដើមចោទ និងចុងចំលើយ ។

ទុកសិទ្ធិអោយគូភាគីប្តឹងឧទ្ធរណ៍រយៈពេល០១ខែគិតពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ក្រឡាបញ្ជី**
**ហត្ថលេខានិងត្រា**
[redacted]

**ចៅក្រម**
**ហត្ថលេខានិងត្រា**
[redacted]

---

បានឃើញ
នៅថ្ងៃទី២២ ខែ០៤ ឆ្នាំ២០២០
**ចៅក្រម**
[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម។
ថ្ងៃពុធ១កើតខែពិសាខឆ្នាំជូតឯកស័កពស២៥៦៣
កំពង់ចាម,ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]

Scanned with CamScanner